សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សំនួរនិងចម្លើយស្តីអំពីសិទ្ធិមនុស្ស (តមកពីលេខមុន)

www.hoksavann.org

ថ្ងៃទី២២ តុលា ២០១២



១១- សំនួរ ៖ អ្វីដែលហៅថា ការពង្រីកសិទ្ធិមនុស្ស និងការពារសិទ្ធិមនុស្ស ?

ចម្លើយ ៖ ការលើកតម្កើងសិទ្ធិមនុស្ស គឺការប្រាប់ពលរដ្ឋឲ្យដឹងថា គេពិតជាមានសិទ្ធិ, អប់រំពលរដ្ឋអំពីប្រភេទនៃសិទ្ធិទាំងនោះ ហើយនិងហ្វឹកហ្វឺនពលរដ្ឋ អំពីរបៀបការពារសិទ្ធិរបស់គេ ។ ពលរដ្ឋត្រូវតែគាំទ្រសិទ្ធិ គឺមានន័យថា លើកស្ទួយនិងទាមទារសិទ្ធិរបស់ខ្លួន ។ ការបង្កើតវិជ្ជាសិទ្ធិមនុស្ស គឺការជំរាបពលរដ្ឋអំពីសិទ្ធិរបស់គេ, អប់រំវិជ្ជាសិទ្ធិមនុស្ស, ហ្វឹកហ្វឺនអំពីរបៀបការពារសិទ្ធិ ហើយនិងលើកស្ទួយ និងទាមទារសិទ្ធិ ។

ការការពារសិទ្ធិបានន័យថា ការខាយាំងកុំឲ្យមានការរំលោភសិទ្ធិ ឬប្រសិនបើមានការរំលោភរួចទៅហើយ ត្រូវតែរកខុសត្រូវឲ្យជនរងគ្រោះ ។

ការការពារសិទ្ធិមនុស្ស តម្រូវឲ្យមានការឃ្លាំមើលយ៉ាងដិតដល់ នូវការប្រព្រឹត្តរបស់អ្នកកាន់អំណាច ។ បើមានការរំលោភសិទ្ធិ ត្រូវតែរាយការណ៍ ដើម្បីផ្សាយជំរាបសាធារណជន ហើយត្រូវតែតវ៉ាប្រឆាំង ។ ធ្វើយ៉ាងនេះទើបរដ្ឋាភិបាល ឬអ្នកកាន់រដ្ឋអំណាចដឹងខ្លួនថា បើហ៊ានរំលោភសិទ្ធិតទៅទៀត គេប្រាកដជានឹងមានឈ្មោះអាក្រក់, មានការទិតៀនពីគ្រប់មជ្ឈដ្ឋាន ព្រមទាំងមានបញ្ហាជាច្រើនទៀតផង ។

កិច្ចការមួយកម្រិតទៀតដែលត្រូវតែធ្វើជាចាំបាច់ គឺការរៀបចំគ្រឹះនៃរចនាសម្ព័ន្ធខាងវិស័យសង្គមនិងនយោបាយឲ្យបានមាំទាំ ដោយមានរួមទាំងប្រព័ន្ធតុលាការ ដែលមានស្វ័យភាព និងមានឥទ្ធិពលគ្រប់គ្រាន់សំរាប់ទប់ទល់ជាមួយក្រសួងទាហាន និងប៉ូលិស ។ បើមានចាប់ជនណាយកទៅឃុំ ត្រូវតែប្រាប់សាមីខ្លួនឲ្យដឹងអំពីសិទ្ធិរបស់គេ, មូលហេតុនៃការចាប់ខ្លួន ហើយនិងជួយសំរួលការផ្តែកច្បាប់ទម្លាប់ឲ្យបានគ្រប់គ្រាន់ និងឲ្យបានឆាប់រហ័សបំផុត ។ អ្នកកាន់អំណាចខាងប៉ូលិសនិងទាហានដែលបានប្រព្រឹត្តបទរំលោភផ្សេងៗ ត្រូវតែនាំខ្លួនទៅតុលាការកាត់ទោស និងដាក់ទណ្ឌកម្មតាមច្បាប់ ដើម្បីជាមេរៀនឲ្យគេដឹងថា ភ្នាក់ងាររដ្ឋការណាដែលប្រព្រឹត្តបទល្មើសដោយរំលោភសិទ្ធិ នឹងត្រូវមានទោស ។

ការពង្រឹងនិងការពារសិទ្ធិមនុស្ស គឺជាការងារពីរក្នុងក្របខ័ណ្ឌតែមួយ ។ ហេតុនេះហើយបានជាគេតែងតែនិយាយអំពីសកម្មភាពទាំងពីរនេះជាមួយគ្នា ។ សរុបសេចក្តីទៅ សកម្មភាពទាំងពីរនេះមានន័យថា ការដឹងឮអំពីសិទ្ធិមនុស្ស ការអប់រំវិជ្ជាសិទ្ធិមនុស្ស ការហ្វឹកហ្វឺនរបៀបការពារសិទ្ធិមនុស្ស ការលើកស្ទួយនិងទាមទារឲ្យមានសិទ្ធិមនុស្ស ហើយនិងការឃ្លាំមើលបទរំលោភសិទ្ធិមនុស្ស ។

១២- សំនួរ ៖ តើគេអាចសំរេចបាននូវសិទ្ធិតាមវិធីណា ?

ចម្លើយ ៖ រដ្ឋាភិបាលទាំងឡាយក្នុងពិភពលោក នាំគ្នាទៅរួមប្រជុំនៅអង្គការសហប្រជាជាតិ ដើម្បីពិភាក្សាអំពីការកំណត់សិទ្ធិមនុស្ស ។ ប៉ុន្តែមានតែមនុស្សលោក ពោលគឺពលរដ្ឋក្នុងលោកនេះទេ ដែលអាចរក្សាទ្រទ្រង់ និងការពារសិទ្ធិរបស់ខ្លួន។

បើនិយាយឲ្យចំទៀតទៅ គឺថាបើគ្រាន់តែកំណត់សិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ និងក្នុងច្បាប់រដ្ឋធម្មនុញ្ញមិនទាន់គ្រប់គ្រាន់មែនទែនទេ ព្រោះថាប្រសិនបើពលរដ្ឋមិនព្រមទាមទារសិទ្ធិសំរាប់ខ្លួនឯង, មិនព្រមហ៊ានចេញមុខការពារសិទ្ធិដោយខ្លួនឯង មិនក្លាហានហ៊ានតវ៉ាប្រឆាំងនឹងការរំលោភសិទ្ធិរបស់ខ្លួនឯងទេនោះ ពួកអ្នកកាន់អំណាចប្រាកដជាយល់ច្រឡំថា ពួកគេអាចប្រព្រឹត្តរំលោភសិទ្ធិបានខ្លះដែរ ដូច្នេះពួកគេក៏ចេះតែប្រព្រឹត្តបំពានលើសិទ្ធិគេឯងតទៅទៀតឥតឈប់ឈរ ។

១៣- សំនួរ ៖ តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីឲ្យមានសិទ្ធិ ?

ចម្លើយ ៖ ដំបូងត្រូវរៀនឲ្យស្គាល់ថាសិទ្ធិគឺជាអ្វី ។ មធ្យោបាយដ៏ល្អបំផុត គឺខំរៀនឲ្យបានហ្មត់ចត់នូវ «សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្ស» ។ បន្ទាប់ទៅទៀត គឺត្រូវបង្កើតជាក្រុមសិទ្ធិមនុស្សប្រចាំភូមិ ឬបង្កើតជាគណៈកម្មាធិការដើម្បីពិនិត្យមើលកុំឲ្យមានការរំលោភសិទ្ធិមនុស្ស ។

១៤- សំនួរ ៖ ប្រសិនបើគេរំលោភលើសិទ្ធិខ្ញុំ តើខ្ញុំត្រូវធ្វើយ៉ាងណា ?

ចម្លើយ ៖ ទី១- ត្រូវរត់ទៅទូលព្រះសង្ឃនៅវត្តណាដែលជិតៗភូមិ អំពីការកើតហេតុ ។

ទី២- កត់ត្រាទុកឲ្យសព្វគ្រប់ នូវអ្វីៗដែលអ្នកបានដឹងឮ ឬឃើញអំពីបទរំលោភនេះ ។ ប្រសិនបើអ្នកមិនប្រសប់សរសេរទេ ត្រូវពឹងអ្នកណាម្នាក់ឲ្យសរសេរឲ្យ ។ ត្រូវកត់ត្រាទុកថ្ងៃ, ខែ, ម៉ោងពេល និងទីកន្លែងកើតហេតុ, ភិនភាគនៃការកើតហេតុបែបផែនដែលអ្នកបានដឹងឮ ឬឃើញ ។

ទី៣- រាយការណ៍អំពីបទរំលោភនេះ ទៅភ្នាក់ងារអង្គការសហប្រជាជាតិ ហើយនិងបញ្ជូនពត៌មានទៅឲ្យអង្គការអន្តរជាតិណាមួយ ដែលធ្វើការខាងវិជ្ជាសិទ្ធិមនុស្ស ។

(នៅមានត)